ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH AUTONOMOUS PORT

កំពង់ផែស្វយ័តភ្នំពេញ

ថ្ងៃ ពុធ ៦ រោច ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព. ស. ២៥៦៥

លេខ.....០៩៦/២២.....ក. ស. ភ.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២២

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបេក្ខជនឈរឈ្មោះជាអភិបាលឯករាជ្យ សម្រាប់អាណត្តិទី៨ នៃក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តភ្នំពេញ

**កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)** ជាសហគ្រាសសាធារណៈ មានទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។ ក. ស. ភ. ជាកំពង់ផែអន្តរជាតិតាមដងទន្លេ ដែលដើរតួនាទីជាប្រតិបត្តិករផែ និងអាជ្ញាធរផែនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក. ស. ភ. មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនទាំងអស់ ឱ្យបានជ្រាបថា ក. ស. ភ. នឹងធ្វើការជ្រើសរើសបេក្ខជន-បេក្ខនារី ដែលមានបំណងឈរឈ្មោះជា អភិបាលឯករាជ្យ ដើម្បីដាក់ជូនមហាសន្និបាតភាគហ៊ុនិក បោះឆ្នោតសម្រេចជ្រើសរើសជា សមាជិកក្រុមប្រឹក្សាភិបាល ក. ស. ភ. សម្រាប់អាណត្តិទី៨ (រយៈពេល ៣ ឆ្នាំ) ដែលគ្រោងនឹងប្រព្រឹត្តទៅនៅអំឡុងខែឧសភា ឆ្នាំ២០២២ ខាងមុខនេះ។

## ១. លក្ខខណ្ឌ និងគុណវុឌ្ឍិនៃការជ្រើសរើស

បេក្ខជន-បេក្ខនារី ដែលមានបំណងដាក់ពាក្យឈរឈ្មោះជាអភិបាលឯករាជ្យ ត្រូវបំពេញលក្ខខណ្ឌ និងមានគុណវុឌ្ឍិ ដូចខាងក្រោម÷

### ក. លក្ខខណ្ឌនៃការជ្រើសរើស

- ត្រូវមានអាយុចាប់ពី ៣៥ ឆ្នាំឡើងទៅ (គិតត្រឹមថ្ងៃដាក់ពាក្យ)
- មិនត្រូវកាន់កាប់មូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតរបស់ ក. ស. ភ. លើសពី ១% នៃមូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតសរុបរបស់ ក. ស. ភ.
- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល ខាងផ្នែកគណនេយ្យ/ហិរញ្ញវត្ថុ
- ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច ៣ ឆ្នាំ ខាងផ្នែកគណនេយ្យ/ហិរញ្ញវត្ថុ
- ចំពោះបេក្ខជន ដែលជាជនបរទេស ត្រូវមានបទពិសោធន៍ការងារក្នុងប្រទេសកម្ពុជា យ៉ាងតិច ៦ ខែ (គិតត្រឹមថ្ងៃដាក់ពាក្យ)
- មិនដែលត្រូវបានផ្តន្ទាទោសជាបទវិន័យរដ្ឋបាល ដែលបញ្ជាក់ដោយអង្គភាពដែលខ្លួនបម្រើការងារ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសតាំង)
- មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួន ដែលបានប្រកាសដោយតុលាការ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសតាំង)



ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ គីវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨២៧ ៨០២ Email: ppapmpwt@online.com.kh

- មិនធ្លាប់ត្រូវបានដកហូតអាជ្ញាបណ្ណ ឬការអនុញ្ញាត ឬត្រូវបានហាមឃាត់បំពេញតួនាទីជាអភិបាល ឬអ្នកគ្រប់គ្រងក្រុមហ៊ុន ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ
- ត្រូវមានលិខិតថ្កោលទោស ដែលបញ្ជាក់ថាមិនធ្លាប់មានទោសក្នុងបទមជ្ឈិម ឬបទឧក្រិដ្ឋ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសតាំង)។

### ខ. គុណវុឌ្ឍិរបស់បេក្ខជនឈរឈ្មោះ

- មិនត្រូវបានជួលដោយ ក. ស. ភ. ក្នុងរយៈពេល ១ ឆ្នាំចុងក្រោយ
- មិនមានទំនាក់ទំនងជាមួយអតិថិជន ឬអ្នកផ្គត់ផ្គង់ដ៏សំខាន់របស់ ក. ស. ភ.
- មិនមានកិច្ចសន្យាផ្ទាល់ខ្លួនជាមួយ ក. ស. ភ. ឬជាមួយបុគ្គលិកជាន់ខ្ពស់របស់ ក. ស. ភ.
- មិនជាប់ទាក់ទងជាមួយអង្គការ ឬសមាគមមិនស្វែងរកប្រាក់ចំណេញណាមួយដែលធ្លាប់ទទួលមូលនិធិពី ក. ស. ភ.
- មិនមែនជាសមាជិកក្រុមគ្រួសាររបស់បុគ្គល ដែលធ្លាប់ធ្វើជាអភិបាលឱ្យ ក. ស. ភ. ឬធ្លាប់បានជួលដោយ ក. ស. ភ. ឱ្យធ្វើជាអគ្គនាយក ឬបុគ្គលិកជាន់ខ្ពស់ក្នុងរយៈពេល ១ ឆ្នាំចុងក្រោយ
- មិនធ្លាប់ធ្វើជាសវនករ ក្នុងរយៈពេល ២ឆ្នាំចុងក្រោយ ឬកំពុងធ្វើជាសវនករឱ្យ ក. ស. ភ.
- ពុំធ្លាប់បម្រើការងារជាបុគ្គលិកជាន់ខ្ពស់ ឬអភិបាលក្នុងក្រុមហ៊ុនធានារ៉ាប់រង ដែលកំពុងផ្តល់សេវាធានារ៉ាប់រងឱ្យ ក. ស. ភ. ឬក្រុមហ៊ុនដែលជាអតិថិជន ឬក្រុមហ៊ុនដែលជាអ្នកផ្គត់ផ្គង់ ឬជាដៃគូប្រកួតប្រជែងរបស់ ក. ស. ភ.
- មិនមែនជានិយោជិតរបស់ ក. ស. ភ. ឬមន្ត្រីរាជការ។

## ២. ការទទួលខុសត្រូវរបស់អភិបាលឯករាជ្យ

- បម្រើការងារក្នុងគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការនានា
- ត្រូវចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ដោយនាំមកនូវការសម្រេចចិត្តឯករាជ្យលើបញ្ហានានា ដូចជាយុទ្ធសាស្ត្រ គោលនយោបាយ ការអនុវត្ត គណនេយ្យភាព ធនធាន ការជ្រើសតាំងបុគ្គលិកជាន់ខ្ពស់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការដឹកនាំ
- ត្រូវឈានមុខគេក្នុងការដោះស្រាយ និងទប់ស្កាត់នូវទំនាស់ផលប្រយោជន៍ ជាសក្តានុពលដែលនឹងអាចកើតឡើង
- ត្រួតពិនិត្យ និងតាមដានយ៉ាងហ្មត់ចត់នូវការអនុវត្តសកម្មភាពការងាររបស់ ក. ស. ភ. ដើម្បីសម្រេចបានតាមគោលបំណង និងគោលដៅដែលបានកំណត់
- ការទទួលខុសត្រូវផ្សេងទៀត តាមការចាំបាច់។

## ៣. អត្ថប្រយោជន៍ដែលទទួលបាន

- ប្រាក់ឧបត្ថម្ភប្រចាំខែ
- ការឧបត្ថម្ភជូននូវប្រេងឥន្ធនៈប្រចាំខែ
- ប្រាក់ថ្លៃងសរសើរប្រចាំឆ្នាំ
- ឧបត្ថម្ភសំលៀកបំពាក់ប្រចាំឆ្នាំ
- ប្រាក់ឧបត្ថម្ភផ្សេងៗទៀត នាឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងបុណ្យភ្ជុំបិណ្ឌ។

### ៤. សំណុំលិខិតក្នុងការដាក់ពាក្យឈរឈ្មោះ

- ជីវប្រវត្តិសង្ខេប (CV) មានបិទរូបថត (៤x៦) ចំនួន ១ ច្បាប់
- លិខិតបង្ហាញចំណាប់អារម្មណ៍ (Cover Letter) ចំនួន ១ ច្បាប់
- សេចក្តីចម្លងសញ្ញាបត្រដែលមានការបញ្ជាក់ត្រឹមត្រូវ ចំនួន ១ ច្បាប់
- លិខិតបញ្ជាក់ការងារ (Recommendation Letter) ចំនួន ១ ច្បាប់
- ឯកសារចាំបាច់ផ្សេងៗទៀត។

### ៥. ទីកន្លែង កាលបរិច្ឆេទ នៃការទទួលពាក្យ និងឈប់ទទួលពាក្យ

- **កាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យ÷** ***ចាប់ពីថ្ងៃទី.....១.....ខែ..មេសា...ឆ្នាំ២០២២*** រៀងរាល់ម៉ោងធ្វើការ (ពេលព្រឹកចាប់ពីម៉ោង ៨:០០-១២:០០ នាទី និងពេលរសៀលចាប់ពីម៉ោង ១៣:៣០ នាទី-១៧:០០ នាទី)
- **កាលបរិច្ឆេទឈប់ទទួលពាក្យ÷** ***នៅថ្ងៃទី.២១. ខែ...មេសា... ឆ្នាំ២០២២*** វេលាម៉ោង ១៧:០០ នាទី
- **ទីកន្លែងទំនាក់ទំនង និងទទួលពាក្យ÷**
  - នៅនាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស ជាន់ទី១ បន្ទប់លេខ ១១០ នៃទីស្នាក់ការកណ្តាល ក. ស. ភ. ដែលមានអាសយដ្ឋាន អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - ឬតាមរយៈសារអេឡិកត្រូនិក÷ ppapmpwt@online.com.kh

សម្រាប់ព័ត៌មានលម្អិត សូមមកទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស ឬតាមរយៈលេខទូរសព្ទ (៨៥៥) ០១០ ៤៤៤ ៣៦៧, (៨៥៥) ០១០ ៤៤៤ ០៨២, (៨៥៥) ០១០ ៤៤៤ ០១៧។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទាំងអស់ទទួលជ្រាបជាព័ត៌មាន។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**ប្រធានអគ្គនាយក**

ហ៊ី_បាវី

**ចម្លងជូន÷**

- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា

*"ដើម្បីគោរពជូនជ្រាប"*

- ផ្សារមូលបត្រកម្ពុជា
- ក្រុមហ៊ុនមូលបត្រ

*"ដើម្បីជូនផ្សព្វផ្សាយ"*

- ឯកសារកាលប្បវត្តិ